ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់បីសាមសិបនាទីល្ងាចនៅ ក្រុមហ៊ុន កូកូរ៉ុល អឺភែរីល(ខេមបូឌា)អ៊ីន មានបើកកិច្ចប្រជុំមួយស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិកមួយចំនួន ដោយមូលហេតុកង្វះវត្ថុធាតុដើម និងអ្នកបញ្ជាទិញលុបចោលការបញ្ជាទិញដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ-១៩។

ការប្រជុំពិភាក្សានេះគឺក្រោមអធិបតីភាពលោកនាយក ប៉ាក់ បូរិន ជានាយកក្រុមហ៊ុន។

<u>សមាសភាពចូលរួមប្រជុំមាន</u>

<u>១/ភាគីរោងចក្រ</u>

១.លោក ប៉ាក់ បូរិន ជានាយករោចក្រ

២.លោក តន់ រតនា ជាប្រធានរដ្ឋបាល

៣.កញ្ញា ហែម សុភត្រ្តា លេខាកត់ត្រា

<u>២/ភាគីខាងតំណាងកម្មករនិយោជិត</u>

១.លោក អ៊ុំ ចន្ទ័មុន្នី ប្រតិភូបុគ្គលិក

២.លោកស្រី ប៉ែន ស្រីអូន ប្រតិភូបុគ្គលិក

៣.លោក ហេង សៅរី ប្រតិភូបុគ្គលិក

ក្រោយពីប្រជុំពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់រួចមកភាគីទាំងពីរបានឈានដល់ការព្រមព្រៀងគ្នាដូចខាងក្រោម:

១)ក្រុមហ៊ុនសំរេចព្យួរកិច្ចសន្យាការងាកម្មករនិយោជិកចំនួន៣៩ ដោយធ្វើការផ្លាស់ប្តូរវេនគ្នា ក្នុងរយះពេល២ខែដោយគិតចាប់ពីថ្ងៃទី២០មេសា រហូតដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០។

៣)ក្នុងអំឡុងពេលនៃព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនបានផ្តល់នូវប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន៣០ដុល្លា។

៣)ក្រុមហ៊ុន រក្សាទុកនូវ មុខងារ តួនាទី ភារកិច្ច និង កន្លែងធ្វើការ របស់បងប្អូនដែលបានព្យួរការងារនៅដដែល។

៤)ប្រសិនបើក្រុមហ៊ុន មានវត្ថុធាតុដើមចូលមកវិញ ក្រុមហ៊ុននឹងហៅកម្មករនិយោជិកមកធ្វើការជាធម្មតាវិញ។

កិច្ចប្រជុំបានចប់សព្វគ្រប់នាវេលាម៉ោងនាថ្ងៃឆ្នាំដដែល។

ធ្វើនៅថ្ងៃព្រហស្បតិ៍០៩រោចខែចេត្រឆ្នាំជូត ទោស័ក ពស២៥៦៣

ភ្នំពេញថ្ងៃទី១៦ខែមេសា ឆ្នាំ២០២០

| | |
|---|---|
| បានឃើញនិងឯកភាព | បានឃើញនិងឯកភាព |
| តំណាងកម្មករ | នាយកក្រុមហ៊ុន |
| អ៊ុំ ចន្ទ័មុន្នី    ប៉ែន ស្រីអូន    ហេង សៅរី | ប៉ាក បូរិន |